No. C22/I/46

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

## អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

**សំណុំរឿងព្រហ្មទណ្ឌ លេខ:** ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៣)

**ចំពោះមុខ:**
ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ០១ កក្កដា ២០០៨

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 01 / JULY / 2008
ម៉ោង (Time/Heure): 14:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. FRY

---

## សេចក្តីសម្រេចលើបញ្ហាបន្ទាន់បន្ទុំដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើង នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន

---

**ការិយាល័យសហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT
យ៉ែត ចរិយា
William SMITH

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 01 / July / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. FRY

**ជនត្រូវចោទ**
អៀង សារី

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
យុង ផានិត
Silke Studzinsky

**សហមេធាវីការពារក្តី**
អាង ឧត្តម
Michael G. KARNAVAS

អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER * CHAMBRE PRELIMINAIRE * E.C.C.C.

១- នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងនូវបញ្ហាបន្ទាន់បង្ខំចំនួនពីរក្នុងពេលសវនាការលើបណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន នៅក្នុងរឿងក្តីរបស់ជនត្រូវចោទ អៀង សារី។

២- បញ្ហាបន្ទាន់បង្ខំទីមួយ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើការជំទាស់នឹងសេចក្តីសម្រេចលើកមុនរបស់អង្គបុរេជំនុំជម្រះដែលមិនអនុញ្ញាតឱ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណី មានរយៈពេលសម្រាប់ធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ស្មើគ្នានឹងរយៈពេលរបស់សហព្រះរាជអាជ្ញា និងសហមេធាវីការពារក្តីលើបញ្ហាឃុំខ្លួនបណ្តោះអាសន្ន។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី មានការរីករាយនឹងទទួលយកសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលស្មើគ្នាលើបញ្ហាដទៃទៀតដូចភាគីផ្សេងទៀតដែរ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា ភាគីទាំងអស់គួរទទួលបានការគោរពដូចៗគ្នា។

៣- អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ភាគីទាំងអស់មានជំហរខុសៗគ្នានៅក្នុងដំណើរការក្តីរឿងព្រហ្មទណ្ឌ ហើយជំហរទាំងនេះថែមទាំងខុសគ្នាទៀតនៅក្នុងដំណាក់កាលនីតិវិធីខុសៗគ្នា។ វិធានផ្ទៃក្នុងចែងពីវិធានមួយចំនួនដែលឆ្លុះបញ្ចាំងពីជំហរខុសៗគ្នាទាំងនោះ។ កាលពីលើកមុន អង្គបុរេជំនុំជម្រះបានធ្វើការសម្រេចជាទូទៅលើជំហររបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងពេលសវនាការលើការឃុំខ្លួនបណ្តោះអាសន្ន ហើយបានផ្តល់សេចក្តីណែនាំអំពីលក្ខណៈទូទៅមួយនៅក្នុងរឿងក្តីលើមុន[1]។

៤- មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងពីសេចក្តីសង្កេតទូទៅជាលាយលក្ខណ៍អក្សរ នៅចំពោះមុខអង្គបុរេជំនុំជម្រះនៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ទាក់ទងនឹងការចេញសេចក្តីសម្រេចសម្អាងហេតុរបស់អង្គជំនុំជម្រះ[2]។ នៅក្នុងពេលសវនាការ គ្មានឃើញទឡ្ហីករណ៍ណាមួយថ្មីត្រូវបានលើកឡើងឡើយ ក្រៅពីតែការចង្អុលបង្ហាញទៅរកគោលការណ៍មួយដែលថា ភាគីទាំងអស់គួរទទួលបានការគោរពដូចៗគ្នា។ អង្គបុរេជំនុំជម្រះយល់ឃើញថា គ្មានគោលការណ៍ទូទៅពាក់ព័ន្ធនឹងរយៈពេលធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់បែបនេះទេ។ ទោះបីជាមានគោលការណ៍ទូទៅនេះក៏ដោយ គោលការណ៍បែបនេះនឹងមានន័យសាមញ្ញថា ចំពោះភាពស្មើគ្នានៃជំហររបស់ពួកគេ ដើមបណ្តឹងរដ្ឋប្បវេណីគួរទទួលបានការគោរពដូចៗគ្នា។ វាមិនមែនជាករណីបែបនេះឡើយ។

[1] សាលដីកាសម្រេចលើការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងបណ្តឹងឧទ្ធរណ៍ចំពោះការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ២០០៨ និងសេចក្តីណែនាំអំពីការធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ក្នុងកំឡុងពេលសវនាការបណ្តឹង ឧទ្ធរណ៍ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០០៨។

[2] សេចក្តីសម្រេចលើការទទួលយកការសង្កេតជាទូទៅ ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០០៨។

PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

៥- ទាក់ទងនឹងបញ្ហាយុត្តាធិការ អង្គបុរេជំនុំជម្រះពិចារណាឃើញថា ដើមបណ្ដឹងរដ្ឋប្បវេណីមានផលប្រយោជន៍ផ្ទាល់ដែលដាច់ដោយឡែកពីផលប្រយោជន៍របស់សហព្រះរាជអាជ្ញា។[៣] ប្រសិនបើអង្គបុរេជំនុំជម្រះធ្វើការសម្រេចថា ពុំមានសិទ្ធិធ្វើបណ្ដឹងអាជ្ញាលើជនត្រូវចោទទេ អាចមានលទ្ធផលថា ដើមបណ្ដឹងរដ្ឋប្បវេណីគ្មានលទ្ធភាពដែលនៅសល់ដើម្បីទាមទារសំណងរបស់ខ្លួន ក្នុងនាមជាដើមបណ្ដឹងរដ្ឋប្បវេណីបានឡើយ។ ករណីនេះវាខុសពីសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការលើកឡើងនូវអំណះអំណាងទាក់ទងនឹងបណ្ដឹងឧទ្ធរណ៍ចំពោះដីកាបង្គាប់ឱ្យឃុំខ្លួន ដោយសារសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលអនុញ្ញាតឱ្យមានបណ្ដឹងឧទ្ធរណ៍នឹងនៅតែអនុញ្ញាតឱ្យដើមបណ្ដឹងរដ្ឋប្បវេណីអាចទាមទារសំណង នៅក្នុងសវនាការលើអង្គសេចក្ដីបានដដែល។

៦- អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា គ្មានទឡ្ហីករណ៍ជាក់លាក់ណាមួយត្រូវបានលើកឡើងថាហេតុអ្វីបានជានៅក្នុងរឿងក្ដីនេះ មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីគួរត្រូវបានផ្ដល់រយៈពេលឱ្យបានយូរជាងមុននោះទេ។ ហេតុផលដូចដែលអង្គបុរេជំនុំជម្រះបានសម្រេចមិនមានការផ្លាស់ប្ដូរនោះឡើយ។ ក្នុងកាលៈទេសៈទាំងនេះ អង្គបុរេជំនុំជម្រះបដិសេធចោលសំណើរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ដែលស្នើសុំការផ្ដល់រយៈពេលយូរជាងមុន នៅក្នុងបញ្ហាឃុំខ្លួនបណ្ដោះអាសន្ន។

៧- មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបានលើកឡើងនូវបញ្ហាបន្ទាន់បន្ទំទីពីរ ដោយស្នើឡើងថា ដើមបណ្ដឹងរដ្ឋប្បវេណី គួរត្រូវបានអនុញ្ញាតឱ្យនិយាយដោយខ្លួនឯងផ្ទាល់ ទោះបីមានមេធាវីតំណាងក៏ដោយ។

៨- កាលពីមុន អង្គបុរេជំនុំជម្រះបានណែនាំថា ដើមបណ្ដឹងរដ្ឋប្បវេណីមិនត្រូវបានអនុញ្ញាតឱ្យឡើងនិយាយ និងផ្ដល់ហេតុផលលើបញ្ហានេះទេ ដោយអនុលោមតាមវិធាន ៧៧(១០) នៃវិធានផ្ទៃក្នុង។ អង្គបុរេជំនុំជម្រះ មិនឃើញមានទឡ្ហីករណ៍ថ្មីណាមួយដែលនឹងនាំដល់ការវិនិច្ឆ័យជាទូទៅផ្សេងៗនោះទេ។

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេច:**

*បដិសេធមិនទទួលយកសំណើរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី។*

ភ្នំពេញ ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន**

[៣] សូមអានវិធាន ២៣(១)(ក)និង(ខ) នៃវិធានផ្ទៃក្នុង។